ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១ ស.រ.ណ.ន

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំព្រះរាជពិធីបុណ្យខួបលើកទី ៩ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងទិវាប្រកាសរដ្ឋធម្មនុញ្ញ

* ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០២ គឺជាទិវាបុណ្យខួបលើកទី ៩ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ **ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** ព្រះមហាក្សត្រជាទីសក្ការៈ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ គឺថ្ងៃនេះហើយ ដែលប្រជារាស្ត្រខ្មែរគ្រប់រូប បានសំដែងឆន្ទៈ និងមនោសញ្ចេតនារបស់ខ្លួនសប្បាយរីករាយយ៉ាងជ្រាលជ្រៅបំផុត ចំពោះ**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ដែលសព្វព្រះរាជហឫទ័យ ទ្រង់គ្រងរាជសម្បត្តិជាថ្មីឡើងវិញ ដើម្បីបានគង់នៅជាម្លប់ដ៏សុខក្សេមក្សាន្តត្រជាក់ត្រជុំរបស់មាតុភូមិ អង្គរ និងប្រជារាស្ត្រខ្មែរ ជាកូន ជាចៅ ចៅទួតរបស់ព្រះអង្គ ។

* ថ្ងៃទី ២៤ ខែ កញ្ញា នេះដែរ ក៏ជាថ្ងៃដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាច្បាប់កំពូល ប្រកបដោយខ្លឹមសារយ៉ាងជ្រាលជ្រៅលើគ្រប់វិស័យដែលសភាធម្មនុញ្ញបានអនុម័ត ត្រូវបានប្រកាសដ៏មហោឡារិក បើកអោយប្រើប្រាស់ជាផ្លូវការក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើឱ្យប្រជារាស្ត្រខ្មែរ ពង្រឹងបានសាមគ្គីភាព ឯកភាពជាតិរឹងមាំ រក្សាការពារបូរណភាពទឹកដី ប្រជាធិបតេយ្យថ្លៃថ្លា និងអរិយធម៌អង្គរដ៏បវរ កសាងប្រទេសជាតិ មានសុខសន្តិភាព និងទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនាអនាគតជាតិ ដើម្បីអភិវឌ្ឍន៍ឈានឡើង និងសំបូររុងរឿង ។

ដើម្បីសំដែងនូវកតញ្ញូតាធម៌ និងថ្វាយព្រះពរសព្ទសាធុការ បវរមហាប្រសើរចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ដែលទ្រង់ប្រកបដោយព្រះមហាករុណាទិគុណ និងព្រហ្មវិហារធម៌ដ៏ថ្លៃថ្លា សូមទ្រង់គង់នៅក្នុងព្រះបរមសិរីរាជសម្បត្តិយូរអង្វែង សំដែងនូវអំណរសាទរ គោរពដោយស្មោះត្រង់ ចំពោះរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំអនុវត្តដូចតទៅ :

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវតុបតែងលំអរចនាដោយភ្លើងពណ៌ តាំងព្រះឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ដោយមានពាក្យស្លោក ថ្វាយព្រះពរ និងសារលិខិតថ្វាយព្រះពរ តាមស្ថាប័ន អង្គភាពរបស់ខ្លួន ព្រមទាំងបំផុសប្រជារាស្ត្រ អោយដោតទង់ជាតិ គ្រប់គេហដ្ឋាន និងបដាអបអរសាទរ តាមពាក្យស្លោកដូចជូនភ្ជាប់ជាមួយនេះ ។

២-គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំពិធីបុណ្យទាំងពីរខាងលើ អោយបានសមស្របតាមលទ្ធភាពជាក់ស្តែង ក្នុងក្របខ័ណ្ឌខេត្ត-ក្រុងនីមួយៗ ដោយមានព្រះសង្ឃក្នុងក្របខ័ណ្ឌខេត្ត-ក្រុង ថ្នាក់ដឹកនាំខេត្ត-ក្រុង មន្ត្រីរាជការនៃមន្ទីរនានា ជុំវិញខេត្ត-ក្រុង ខ័ណ្ឌ-ស្រុក អ្នកមុខអ្នកការ ប្រជាពលរដ្ឋចូលរួមអោយបានឧឡារិក ព្រមទាំងមានកម្មវិធីចុះសួរសុខទុក្ខតាមមន្ទីរពេទ្យ មណ្ឌលកុមារកំព្រាផង ។

៣-ក្រសួងពត៌មាន ត្រូវណែនាំចាត់អោយបណ្តាញវិទ្យុ ទូរទស្សន៍ជាតិ និងឯកជនតាមដានយកពត៌មាន ធ្វើការផលិត ផ្សព្វផ្សាយ ឃោសនា នូវព្រះរាជសកម្មភាព និងស្នាព្រះហស្ត **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** និងខ្លឹមសារនៃរដ្ឋធម្មនុញ្ញ ។

៤-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈបុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តសប្បាយ នៅតាមទីសាធារណៈ ដើម្បីចូលរួមអបអរសាទរក្នុងទិវា ជាប្រវត្តិសាស្ត្រនេះ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០២ ។

៥-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាព ក្រោមឱវាទអោយសហការ ការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម បំរើការរៀបចំពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះមហាក្សត្រ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ ឱ្យធានាបានសុវត្ថិភាព និងសប្បាយរីករាយ ។

៦-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវមានផែនការបែងចែកតាមក្រសួង រដ្ឋលេខាធិការដ្ឋាន មន្ទីរ ស្ថាប័ន អំពាវនាវសប្បុរសជន អង្គការក្រៅរដ្ឋាភិបាល, អង្គការមនុស្សធម៌ ក្រុមហ៊ុនឯកជន ជួយឧបត្ថម្ភជាថវិកា សម្ភារៈ គ្រឿងឧបភោគ បរិភោគផ្សេងៗ ចុះសួរសុខទុក្ខដល់អ្នករបួស មានជម្ងឺកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ, យុទ្ធជនពិការតាមមណ្ឌលពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យគ្មានទីពឹង ដើម្បីសំដែងមនោសញ្ចេតនាអាណិតស្រឡាញ់រាប់អាន លើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក ។

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត-ក្រុង ចាត់តាំងអនុវត្តតាមស្មារតីនៃសារាចរណែនាំនេះ ឱ្យបានសំរេចលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ